45 សំណើ ការធានារ៉ាប់រងការថែទាំសុខភាព។ ការផ្លាស់ប្តូរអត្រាតម្លៃ។ បញ្ញត្តិផ្ទួចផ្តើម។

ចំណងជើងផ្លូវការ និងសេចក្តីសង្ខេប **បានរៀបចំឡើងដោយអគ្គមេធាវី**

ការធានារ៉ាប់រងការថែទាំសុខភាព។ ការផ្លាស់ប្តូរអត្រាតម្លៃ។ បញ្ញត្តិផ្ទួចផ្តើម។

- តម្រូវថាការផ្លាស់ប្តូរអត្រាតម្លៃការធានារ៉ាប់រងសុខភាព ឬអ្វីផ្សេងទៀត ដែលប៉ះពាល់ដល់តម្លៃសេវាពាក់ព័ន្ធនឹងការធានារ៉ាប់រងសុខភាព ត្រូវបានអនុម័តដោយស្នងការធានារ៉ាប់រង មុនពេលចូលជាធរមាន។
- ផ្តល់ជូនជាសាធារណៈនូវសេចក្តីជូនដំណឹង ការលាតត្រដាង និងសវនាការ អំពីការផ្លាស់ប្តូរអត្រាតម្លៃធានារ៉ាប់រងសុខភាព និងការពិនិត្យរឿងក្តីឡើងវិញជាបន្តបន្ទាប់។
- តម្រូវឲ្យមានសេចក្តីថ្លែងសច្ចាដោយក្រុមហ៊ុនធានារ៉ាប់រងសុខភាព អំពីសុក្រឹតភាពនៃព័ត៌មាន ដែលបានដាក់ជូនស្នងការធានារ៉ាប់រង ដើម្បីបញ្ជាក់ភាពសមហេតុផលនៃការផ្លាស់ប្តូរអត្រាតម្លៃ។
- មិនអនុវត្តចំពោះគម្រោងសុខភាពជាក្រុមធំៗរបស់និយោជកឡើយ។
- ហាមក្រុមហ៊ុនធានារ៉ាប់រងសុខភាព រថយន្ត និងផ្ទះសម្បែង ពីការកំណត់លក្ខណៈសម្បត្តិសម្រាប់កិច្ចសន្យាធានារ៉ាប់រង ឬកំណត់អត្រាតម្លៃ ដោយអាស្រ័យលើកង្វះធានារ៉ាប់រងនាពេលមុន ឬប្រវត្តិឥណទាននោះឡើយ។

សេចក្តីសង្ខេបនៃការវិភាគរបស់អង្គនីតិបញ្ញត្តិអំពីការប៉ាន់ប្រមាណនៃផលប៉ះពាល់សារពើពន្ធសុទ្ធសាធារណៈរបស់រដ្ឋាភិបាលថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋាន ៖

- បានធ្វើឲ្យកើនចំណាយរដ្ឋបាលរបស់រដ្ឋ ដើម្បីធ្វើនិយ័តកម្មការធានារ៉ាប់រងសុខភាព ដែលទំនងជាមិនលើសពីចំនួនក្រោមរាប់សិបលានដុល្លារប្រចាំឆ្នាំ ក្នុងឆ្នាំភាគច្រើន ដែលផ្តល់មូលនិធិពីកម្រៃដែលត្រូវបានបង់ដោយក្រុមហ៊ុនធានារ៉ាប់រងទាំងឡាយ។

ការវិភាគដោយអ្នកវិភាគនីតិបញ្ញត្តិ

សាវតារ

វិធានការនេះតម្រូវឲ្យស្នងការការធានារ៉ាប់រង (ស្នងការ) អនុម័តអត្រាតម្លៃនានាសម្រាប់ប្រភេទធានារ៉ាប់រងសុខភាពមួយចំនួន ។ ដំណើរការអនុម័តអត្រាតម្លៃនឹងមានលក្ខណៈប្រហាក់ប្រហែលទៅនឹងដំណើរការមួយដែលត្រូវបានប្រើប្រាស់យ៉ាងត្រឹមត្រូវសម្រាប់ប្រភេទធានារ៉ាប់រងផ្សេងទៀត ដូចជា ការធានារ៉ាប់រងរថយន្ត និងការធានារ៉ាប់រងផ្ទះសម្បែងជាដើម ។ ខាងក្រោម យើងផ្តល់ព័ត៌មានសាវតារស្តីពីការធានារ៉ាប់រងសុខភាពក្នុងរដ្ឋ California និងបទប្បញ្ញត្តិអត្រាតម្លៃធានារ៉ាប់រងរថយន្ត និងផ្ទះសម្បែង ។

ការធានារ៉ាប់រងសុខភាពនៅរដ្ឋ California ។

ប្រភេទនានានៃការធានារ៉ាប់រងសុខភាព ។ ដូចដែលបានបង្ហាញក្នុងរូបទី 1 ប្រជាពលរដ្ឋ California ទទួលការធានារ៉ាប់រងសុខភាពតាមរបៀបជាច្រើនផ្សេងៗគ្នា ។ បុគ្គល និងគ្រួសារខ្លះទទួលការធានារ៉ាប់រងសុខភាពពីកម្មវិធីនានារបស់រដ្ឋាភិបាល ដូចជា កម្មវិធី មេឌីឃារ ឬ មេឌីខេដ (ហៅថា Medi-Cal ក្នុងរដ្ឋ California) ។ បុគ្គល និងគ្រួសារផ្សេងទៀតទទួលការធានារ៉ាប់រងសុខភាពដោយផ្អែកលើការងារពីនិយោជករបស់ពួកគេ ។ ការធានារ៉ាប់រងសុខភាពដោយផ្អែកលើការងារដែលផ្តល់ដោយក្រុមហ៊ុននានាដែលមាននិយោជិតលើសពី 50 នាក់ ត្រូវបានគេហៅថា ការធានារ៉ាប់រងជាក្រុមធំ ។ ការធានារ៉ាប់រងដែលផ្តល់ដោយក្រុមហ៊ុននានាដែលមាននិយោជិត 50 នាក់ ឬតិចជាងនេះ ត្រូវបានគេហៅថា ការធានារ៉ាប់រងជាក្រុមតូច ។ ម្យ៉ាងវិញទៀតបុគ្គល និងគ្រួសារផ្សេងៗទៀតទិញការធានារ៉ាប់រងសុខភាពដោយផ្ទាល់ពីក្រុមហ៊ុនធានារ៉ាប់រងសុខភាពមួយ (ត្រូវបានគេហៅថា ការធានារ៉ាប់រងសុខភាពជាលក្ខណៈបុគ្គល) ។ វិធានការនេះអនុវត្តជាចម្បងចំពោះការធានារ៉ាប់រងជាលក្ខណៈបុគ្គល និងជាក្រុមតូច—ដែលគ្របដណ្តប់លើប្រជាពលរដ្ឋ California ប្រហែល 6 លាននាក់ ឬស្មើនឹង 16 ភាគរយនៃប្រជាពលរដ្ឋសរុប ។

ក្រសួងរដ្ឋចំនួនពីរគ្រប់គ្រងការធានារ៉ាប់រងសុខភាពនៅរដ្ឋ California ។ ផលិតផលធានារ៉ាប់រងសុខភាពភាគច្រើនដែលត្រូវបានលក់ក្នុងរដ្ឋ California ត្រូវតែទទួលបានការអនុម័តពីនិយ័តករនានារបស់រដ្ឋ ដើម្បីធានាថា ផលិតផលទាំងនោះគោរពទៅតាមលក្ខខណ្ឌផ្សេងៗរបស់រដ្ឋ ។ ឧទាហរណ៍ ៖ ក្រុមហ៊ុនធានារ៉ាប់រងសុខភាពទាំងឡាយត្រូវផ្តល់អត្ថប្រយោជន៍មូលដ្ឋានដល់អ្នកចុះឈ្មោះ—ដូចជា ការទៅជួបគ្រូពេទ្យ ការសម្រាកនៅពេទ្យ និងថ្នាំតាមវេជ្ជបញ្ជា—និងមានចំនួនគ្រូពេទ្យគ្រប់គ្រាន់ដើម្បីផ្តល់ការថែទាំឲ្យបានទាន់ពេលវេលា ។ លក្ខខណ្ឌទាំងនេះជាទូទៅត្រូវបានពង្រឹងដោយក្រសួងថែទាំសុខភាពដែលត្រូវបានគ្រប់គ្រង (DMHC) ឬក្រសួងធានារ៉ាប់រងរដ្ឋ California (CDI)។ ក្រសួងគ្រប់គ្រងការថែទាំសុខភាពត្រូវបានដំណើរការដោយនាយកមួយរូបដែលចាត់តាំងដោយអភិបាលរដ្ឋ ហើយក្រសួងនេះគ្រប់គ្រងប្រភេទធានារ៉ាប់រងសុខភាពមួយចំនួន ។ CDI ត្រូវបានដំណើរការដោយស្នងការដែលត្រូវបានបោះឆ្នោតជ្រើសតាំង ហើយក្រសួងនេះគ្រប់គ្រងប្រភេទធានារ៉ាប់រងសុខភាពផ្សេងទៀត ។ ប្រជាពលរដ្ឋ California ដែលត្រូវបានធានារ៉ាប់រងភាគច្រើន មានការធានារ៉ាប់រងសុខភាពដែលត្រូវបានគ្រប់គ្រងដោយ DMHC ។ បទប្បញ្ញត្តិនៃការធានារ៉ាប់រងសុខភាពជាលក្ខណៈបុគ្គល ឬជាក្រុមតូចរបស់រដ្ឋ California ត្រូវបានញែកដោយស្មើតាមរបៀបណាមួយនោះរវាង DMHC និង CDI ។ ការ

ការវិភាគដោយអ្នកវិភាគនីតិបញ្ញត្តិ **ត**

រូបភាព 1
តើប្រជាពលរដ្ឋ California ទទួលបានធានារ៉ាប់រងសុខភាពនៅទីណា?



ចំណាយលើសកម្មភាពនានារបស់ក្រសួងនីមួយៗ ជាទូទៅត្រូវបានផ្តល់មូលនិធិតាមរយៈកម្រៃនានាដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងទាំងឡាយដែលស្ថិតក្រោមការគ្រប់គ្រង ។ ប្រភេទធានារ៉ាប់រងផ្សេងៗទៀតមួយចំនួនដូចជា កម្មវិធីមេឌីឃារ សហព័ន្ធ ជាទូទៅមិនមានជាកម្មវត្ថុទៅនឹងលក្ខខណ្ឌនានារបស់រដ្ឋនោះទេ ហើយដូច្នេះមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងណាមួយនោះទេ ។

ការពិនិត្យមើលឡើងវិញ តែមិនមែនជាការអនុម័ត នូវអត្រាតម្លៃធានារ៉ាប់រងសុខភាព ។ គិតត្រឹមឆ្នាំ 2011 ក្រុមហ៊ុនធានារ៉ាប់រងសុខភាពនានាត្រូវបញ្ជូនព័ត៌មានស្តីពីអត្រាតម្លៃនានាដែលត្រូវបានស្នើឡើងសម្រាប់ការធានារ៉ាប់រងសុខភាពជាលក្ខណៈបុគ្គល និងជាក្រុមតូចដែលស្ថិតជាមួយនឹង DMHC ឬ CDI មុនពេលអត្រាតម្លៃទាំងនោះអាចចូលជាធរមានបាន ។ (ក្រុមហ៊ុនធានារ៉ាប់រងសុខភាពនានាមិនតម្រូវឲ្យបញ្ជូលព័ត៌មានស្តីពីអត្រាតម្លៃសម្រាប់ការធានារ៉ាប់រងជាក្រុមធំនោះទេ) ។ ទាំង DMHC និង CDI ពិនិត្យមើលព័ត៌មានស្តីពីអត្រាតម្លៃ និងឆ្លើយតបថាតើការដំឡើងអត្រាតម្លៃសមហេតុផលឬអត់។ នៅពេលវាយតម្លៃលើភាពសមហេតុផលនៃអត្រាតម្លៃធានារ៉ាប់រងសុខភាព DMHC និង CDI អាចពិចារណាលើប្រភេទនៃកត្តាផ្សេងៗ ដូចជា ៖ (1) អត្ថប្រយោជន៍ផ្ទៃសាស្ត្រអ្វីខ្លះដែលត្រូវបានធានា (2) ចំណែកនៃការចំណាយប៉ុន្មានដែលអ្នកចុះឈ្មោះត្រូវបង់តាមរយៈសហការទូទាត់ និងការចំណាយត្រូវបង់ និង (3) ថាតើ ការចំណាយនានាផ្នែករដ្ឋបាលរបស់ក្រុមហ៊ុនមួយសមហេតុផលឬយ៉ាងណា ។ ក្រសួងទាំងពីរក៏ត្រូវបានតម្រូវឲ្យបញ្ចេញព័ត៌មានមួយចំនួនស្តីពីការពិនិត្យមើលទាំងនេះទៅកាន់សាធារណៈជននៅលើគេហទំព័ររបស់ខ្លួនផងដែរ ។ ទោះយ៉ាងណា DMHC និង CDI មិនមានសិទ្ធិអំណាចច្រានចោល ឬអនុម័តអត្រាតម្លៃ មុនពេលអត្រាតម្លៃទាំងនេះចូលជាធរមាននោះទេ ។

កំណែទម្រង់ការថែទាំសុខភាពសហព័ន្ធបង្កើតទីផ្សារជួញដូរអត្ថប្រយោជន៍សុខភាពនានា ។ ច្បាប់ស្តីពីការការពារអ្នកជំងឺ និងការថែទាំដែលមានតម្លៃសមរម្យនៃសហព័ន្ធ ដែលត្រូវបានអនុម័តក្នុងឆ្នាំ 2010 ដែលត្រូវបានគេនិយាយយោងផងដែរថាជាកំណែទម្រង់ការថែទាំសុខភាពសហព័ន្ធនោះ បានបង្កើតទីផ្សារនានា ហៅថា ទីផ្សារជួញដូរអត្ថប្រយោជន៍សុខភាព ។ ក្រុមហ៊ុនធានារ៉ាប់រងសុខភាពនានា អាចលក់ផលិតផលធានារ៉ាប់រងសុខភាពផ្សេងៗទៅកាន់បុគ្គលនានា និងអាជីវកម្មខ្នាតតូចផ្សេងៗនៅលើទីផ្សារជួញដូរទាំងនេះ ។ បុគ្គលនិងគ្រួសារដែលមានប្រាក់ចំណូលទាប និងមធ្យមមួយចំនួនអាចទទួលបានការឧបត្ថម្ភធនពីសហព័ន្ធ ដើម្បីឲ្យការធានារ៉ាប់រងសុខភាពរបស់ពួកគេកាន់តែមានតម្លៃថោកសមរម្យ ។ ការឧបត្ថម្ភធនសហព័ន្ធទាំងនេះ មិនមាននោះទេសម្រាប់ការធានារ៉ាប់រងដែលត្រូវបានទិញខាងក្រៅទីផ្សារជួញដូរនោះ ។ ទីផ្សារជួញដូររបស់រដ្ឋ California—ដែលបានប្រតិបត្តិការចាប់ពីខែតុលា ឆ្នាំ 2013 មក—ត្រូវបានគេស្គាល់ឈ្មោះថា Covered California ហើយទីផ្សារនេះ ត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាមួយដែលមានសមាជិកចំនួនប្រាំរូប (ក្រុមប្រឹក្សា) ដែលរួមមានបុគ្គលនានាដែលត្រូវបានតែងតាំងដោយអភិបាលរដ្ឋ និងអង្គនីតិបញ្ញត្តិ។ Covered California បច្ចុប្បន្នត្រូវបានផ្តល់មូលនិធិដោយមូលនិធិនានារបស់

សហព័ន្ធ និងកម្រៃផ្សេងៗត្រូវបានវាយតម្លៃលើបណ្តាក្រុមហ៊ុនធានារ៉ាប់រងសុខភាពដែលចូលរួម ។

ក្រុមប្រឹក្សានៃ Covered California ចរចាជាមួយបណ្តាក្រុមហ៊ុនធានារ៉ាប់រងសុខភាព ។ ស្ថិតនៅក្រោមច្បាប់រដ្ឋ ក្រុមប្រឹក្សានេះមានសិទ្ធិអំណាចអនុម័តថាតើផលិតផលធានារ៉ាប់រងណាខ្លះត្រូវលក់តាមរយៈ Covered California ដែលជាកម្មវត្ថុទៅនឹងលក្ខខណ្ឌនានារបស់រដ្ឋ និងសហព័ន្ធ ។ ដូច្នេះ ក្រុមប្រឹក្សានេះចរចាអំពីលក្ខណៈគម្រោងធានារ៉ាប់រងជាក់លាក់មួយចំនួន—ដូចជា អត្រាតម្លៃ—ជាមួយបណ្តាក្រុមហ៊ុនធានារ៉ាប់រងសុខភាព ដែលស្វះស្វែងលក់ផលិតផលផ្សេងៗតាមរយៈ Covered California ។

ការធានារ៉ាប់រងសុខភាពសម្រាប់ទីផ្សារជាលក្ខណៈបុគ្គលត្រូវបានលក់ក្នុងអំឡុងពេលនៃ "ការចុះឈ្មោះចំហ" ។ ជាទូទៅ មនុស្សទាំងឡាយអាចចុះឈ្មោះទិញការធានារ៉ាប់រងសុខភាពសម្រាប់ទីផ្សារជាលក្ខណៈបុគ្គលតែក្នុងអំឡុងពេលប៉ុន្មានខែតែប៉ុណ្ណោះ ឬក្នុងអំឡុងពេលចុះឈ្មោះចំហ ។ ជាទូទៅ ការចុះឈ្មោះចំហចាប់ផ្តើមក្នុងរដូវស្លឹកឈើជ្រុះ និងមានរយៈពេលពីរបីខែ ។

បទប្បញ្ញត្តិអត្រាតម្លៃការធានារ៉ាប់រងរថយន្ត និងការធានារ៉ាប់រងផ្ទះសម្បែង

ការធានារ៉ាប់រងរថយន្ត និងការធានារ៉ាប់រងផ្ទះសម្បែង ជាកម្មវត្ថុនៃដំណើរការអនុម័តអត្រាតម្លៃ ។ ក្នុងឆ្នាំ 1988 អ្នកបោះឆ្នោតរដ្ឋ California បានអនុម័តសេចក្តីស្នើលេខ 103 ដែលតម្រូវឲ្យអត្រាតម្លៃនានាសម្រាប់ប្រភេទធានារ៉ាប់រងមួយចំនួន—រួមទាំងការធានារ៉ាប់រងរថយន្ត និងការធានារ៉ាប់រងផ្ទះសម្បែង—មិនឲ្យមានតម្លៃខ្ពស់ហួសហេតុ មានភាពសមស្រប ឬមិនឲ្យមានការរើសអើងប្រកបដោយភាពអយុត្តិធម៌នោះទេ ។ (ការធានារ៉ាប់រងសុខភាពមិនមែនជាកម្មវត្ថុចំពោះលក្ខខណ្ឌតម្រូវនៃសេចក្តីស្នើលេខ 103 នោះទេ) ។ សេចក្តីស្នើលេខ 103 តម្រូវឲ្យស្នងការពិនិត្យមើលឡើងវិញ និងអនុម័តសំណើអត្រាតម្លៃនានាមុនពេលអត្រាតម្លៃទាំងនោះចូលជាធរមាន ។ ស្នងការអាចបើកសវនាការជាសាធារណៈមួយសម្រាប់អត្រាតម្លៃណាមួយដែលត្រូវបានស្នើឡើង ។ លើសពីនេះទៀត អ្នកប្រើប្រាស់ម្នាក់ ឬអ្នកតំណាងអ្នកប្រើប្រាស់ម្នាក់អាចតវ៉ាទៅនឹងអត្រាតម្លៃដែលត្រូវបានស្នើឡើង និងស្នើឲ្យមានសវនាការជាសាធារណៈមួយ ។ ស្នងការត្រូវបានតម្រូវឲ្យផ្តល់តាមសំណើសុំសវនាការជាសាធារណៈមួយ នៅពេលការផ្លាស់ប្តូរអត្រាតម្លៃដែលត្រូវបានស្នើឡើងមានកម្រិតលើសភាគរយជាក់លាក់មួយចំនួន ។ ស្នងការមានសិទ្ធិអំណាចជាចុងក្រោយក្នុងការអនុម័ត ឬច្រានចោលអត្រាតម្លៃនានាដែលត្រូវបានស្នើឡើង ។ សេចក្តីសម្រេចរបស់ស្នងការអំពីអត្រាតម្លៃ អាចត្រូវបានប្តឹងឧទ្ធរណ៍ទៅកាន់តុលាការដោយអ្នកប្រើប្រាស់ អ្នកតំណាងអ្នកប្រើប្រាស់ ឬក្រុមហ៊ុនធានារ៉ាប់រងនានា ។

សំណើ

អត្រាតម្លៃសម្រាប់ការធានារ៉ាប់រងសុខភាពជាលក្ខណៈបុគ្គល និងជាក្រុមតូច ត្រូវតែអនុម័តដោយស្នងការ ។ វិធានការនេះធ្វើឲ្យអត្រាតម្លៃនានាសម្រាប់ការធានារ៉ាប់រងសុខភាពជាលក្ខណៈបុគ្គល និងជាក្រុមតូចនាពេលបច្ចុប្បន្ន និងអនាគត—រួមទាំងអត្រាតម្លៃនានាសម្រាប់ការធានារ៉ាប់រងសុខភាពដែលត្រូវបានគ្រប់គ្រងដោយ CDI ឬ DMHC—ជាកម្មវត្ថុទៅនឹងដំណើរការអនុម័តអត្រាតម្លៃ ដែលត្រូវបានបង្កើតឡើងស្ថិតក្រោមសេចក្តីស្នើលេខ 103 ។ វិធានការនេះក៏ចែងថា អត្រាតម្លៃនានាដែលត្រូវបានស្នើឡើងក្រោយថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2012 ត្រូវតែអនុម័តដោយស្នងការ ហើយការបង់ចំណាយផ្នែកលើអត្រាតម្លៃនានាដែលអនុវត្តនៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2012 ជាកម្មវត្ថុចំពោះការបង្វិលសងវិញ ។ មានភាពមិនប្រាកដប្រជាផ្នែកច្បាប់មួយចំនួនអំពី ថាតើស្នងការអាចតម្រូវឲ្យក្រុមហ៊ុនធានារ៉ាប់រងសុខភាពនានាបង្វិលសងវិញដែរឬយ៉ាងណា សម្រាប់ការធានារ៉ាប់រងដែលលែងអនុវត្តបាននោះ ។

វិធានការនេះក៏កំណត់ន័យយ៉ាងទូលំទូលាយនៃពាក្យ "អត្រាតម្លៃ" ក្នុងរបៀបមួយដែលរួមបញ្ចូលទាំងកត្តាផ្សេងៗលើសពីបុព្វលាភធានារ៉ាប់រង ដូចជា អត្ថប្រយោជន៍ សហការទូទាត់ និងការចំណាយត្រូវបង់ ។ បើទោះជាមានភាពមិនប្រាកដប្រជាមួយចំនួនទាក់ទងនឹង ថាតើបញ្ញត្តិនេះនឹងត្រូវបានបកស្រាយយ៉ាងដូចម្តេចនោះ វាទំនងជានឹងមិនផ្តល់ឲ្យស្នងការនូវសិទ្ធិអំណាចថ្មីណាមួយដើម្បីអនុម័តលក្ខណៈនានានៃផលិតផលធានារ៉ាប់រងសុខភាព ក្រៅពីបុព្វលាភធានារ៉ាប់រង ដូចជា ប្រភេទផ្សេងនៃអត្ថប្រយោជន៍ដែលបានធានារ៉ាប់រងនោះទេ ។

សិទ្ធិអំណាចគ្រប់គ្រងរបស់ DMHC ដែលមានស្រាប់នឹងអាចនៅតែមានដដែល ។ ស្ថិតក្រោមវិធានការនេះ DMHC នឹងបន្តគ្រប់គ្រងប្រភេទនានានៃការធានារ៉ាប់រង ហើយមានសិទ្ធិអំណាចក្នុងការ*ពិនិត្យមើលឡើងវិញ*នូវអត្រាតម្លៃធានារ៉ាប់រងសុខភាពមួយចំនួន ។ ទោះជាយ៉ាងណា ស្នងការនឹងអាចមានសិទ្ធិអំណាចតែឯងដើម្បី *អនុម័ត*អត្រាតម្លៃនានា ។

កម្រៃដាក់ឥណ្ឌល់ឯកសារធានារ៉ាប់រងដែលត្រូវបានប្រមូល ដើម្បីប្រើប្រាស់សម្រាប់ការចំណាយផ្នែករដ្ឋបាលរបស់រដ្ឋ ។ ការចំណាយបន្ថែមផ្នែករដ្ឋបាលណាមួយចំពោះ CDI ដែលបណ្តាលមកពីវិធានការនេះ នឹងត្រូវបានផ្តល់ហិរញ្ញវត្ថុដោយកម្រៃកើនឡើងដែលបង់ដោយក្រុមហ៊ុនធានារ៉ាប់រងសុខភាពនានា ។

ការហាមឃាត់ចំពោះការពិចារណាលើប្រវត្តិឥណទាន និងវិសាលភាពធានារ៉ាប់រងពីមុន ។ វិធានការនេះក៏ហាមឃាត់ការប្រើប្រាស់ប្រវត្តិឥណទាន ឬភាពគ្មានវិសាលភាពធានារ៉ាប់រងពីមុនរបស់បុគ្គលណាម្នាក់ ដើម្បីកំណត់អត្រាតម្លៃ ឬភាពមានសិទ្ធិទទួលបានការធានារ៉ាប់រងសុខភាព រថយន្ត និងផ្ទះសម្បែងផងដែរ។ ច្បាប់បច្ចុប្បន្ន ហាមឃាត់ជាទូទៅរួចហើយនូវការប្រើប្រាស់កត្តាទាំងនេះនៅពេលកំណត់អត្រាតម្លៃ ឬភាពមានសិទ្ធិទទួលបានការធានារ៉ាប់រងសុខភាព ។ ច្បាប់បច្ចុប្បន្ន អនុញ្ញាតឲ្យប្រើប្រាស់មួយចំនួននូវប្រវត្តិឥណទាន ឬវិសាលភាពធានារ៉ាប់រងពីមុន នៅពេលកំណត់អត្រាតម្លៃ ឬភាពមានសិទ្ធិទទួលបានការធានារ៉ាប់រងរថយន្ត និងផ្ទះសម្បែង ។ ទោះជាយ៉ាងណា ក្នុងការអនុវត្ត ក្រុមហ៊ុនធានារ៉ាប់រងនានាជាទូទៅមិនបានប្រើប្រាស់កត្តាទាំងនេះឡើយ ។

ការវិភាគដោយអ្នកវិភាគនីតិបញ្ញត្តិ

ត

លទ្ធផលសារពើពន្ធ

លទ្ធផលសារពើពន្ធសំខាន់បំផុតនៃវិធានការនេះទៅលើរដ្ឋាភិបាលថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋាន ដូចដែលបានពិពណ៌នាលម្អិតខាងក្រោម គឺស្ថិតលើការចំណាយនានាលើផ្នែករដ្ឋបាលរបស់រដ្ឋ ។ ចំនួនសុទ្ធនៃការចំណាយបន្ថែមផ្នែករដ្ឋបាលរបស់រដ្ឋពីវិធានការនេះ នឹងទំនងជា**មិនលើសពីចំនួនក្រោមប៉ុន្មានលានដុល្លារក្នុងមួយឆ្នាំ។នោះទេ ប៉ុន្តែអាចនឹងកើនឡើងខ្ពស់ជាងនេះក្នុងឆ្នាំខ្លះ** ។ ការចំណាយទាំងនេះនឹងត្រូវបានផ្តល់មូលនិធិពីប្រាក់ចំណូលពីកម្រៃបន្ថែមដែលបានប្រមូលពីក្រុមហ៊ុនធានារ៉ាប់រងសុខភាពនានា ។

ការចំណាយនានាផ្នែករដ្ឋបាលរបស់រដ្ឋដែលត្រូវបានបង្កើនសម្រាប់ CDI។ វិធានការនេះនឹងនាំមកនូវចំណាយបន្ថែមសម្រាប់ CDI រួមទាំងការចំណាយដើម្បីពិនិត្យមើលឡើងវិញ និងអនុម័តអត្រាតម្លៃការធានារ៉ាប់រងសុខភាព និងរៀបចំសវនាការជាសាធារណៈស្តីពីអត្រាតម្លៃដែលបានស្នើ ។ ការចំណាយដែលមានជាប់ជាបន្តទាំងនេះនឹងទំនងជាមិនលើសពីក្រោមប៉ុន្មានលានដុល្លារក្នុងមួយឆ្នាំ។ឡើយ ។ បរិមាណនៃការចំណាយបន្ថែម នឹងអាស្រ័យលើកត្តាមួយចំនួនរួមទាំងភាពញឹកញាប់ដែល CDI ឬអ្នកតំណាងអតិថិជនតវ៉ាចំពោះអត្រាតម្លៃដែលត្រូវបានស្នើឡើង ។ ការចំណាយអាចមានចំនួនខ្ពស់ជាងនេះបន្តិចបន្តួចក្នុងរយៈពេលប៉ុន្មានឆ្នាំដំបូង បន្ទាប់ពីវិធានការនេះចូលជាធរមាន ។ ឧទាហរណ៍ ៖ នឹងមានការចំណាយបន្ថែមតែម្តង ប្រសិនបើ CDI បានវាយតម្លៃឡើងវិញលើអត្រាតម្លៃនានា ដែលបច្ចុប្បន្នកំពុងអនុវត្ត ។

ឥទ្ធិពលមិនច្បាស់លាស់ផ្សេង។ទៅលើការចំណាយផ្នែករដ្ឋបាលរបស់ DMHC ។ វិធានការនេះមិនដាក់ភារកិច្ចថ្មីដោយផ្ទាល់លើ DMHC នោះទេ ប៉ុន្តែវាអាចជះឥទ្ធិពលលើការចំណាយផ្នែករដ្ឋបាលរបស់ DMHC ។ ទិសដៅ និងវិសាលភាពនៃឥទ្ធិពលដែលអាចកើតមាននេះ គឺមិនច្បាស់លាស់នោះទេ ។ ឧទាហរណ៍ ៖ ក្នុងពេលមួយ កម្រិតដែល DMHC នឹងបន្តពិនិត្យមើលឡើងវិញនូវអត្រាតម្លៃនានាសម្រាប់ការធានារ៉ាប់រងសុខភាពទាក់ទងនឹងសិទ្ធិអំណាចក្នុងការអនុម័តអត្រាតម្លៃដែលត្រូវបានផ្តល់ទៅឲ្យ CDI ស្ថិតក្រោមវិធានការនេះ មានភាពមិនច្បាស់លាស់ ។ ប្រសិនបើ DMHC បានកាត់បន្ថយ ឬលុបបំបាត់សកម្មភាពពិនិត្យមើលឡើងវិញនូវអត្រាតម្លៃរបស់ខ្លួន ការណ៍នេះនឹងជួយសន្សំការចំណាយផ្នែករដ្ឋបាលរហូតដល់រាប់សែនដុល្លារក្នុងមួយឆ្នាំ។ ។ ម្យ៉ាងវិញទៀត ការចំណាយមួយចំនួនផ្នែករដ្ឋបាលរបស់ DMHC អាចកើនឡើងស្ថិតក្រោមវិធានការនេះ ប្រសិនបើចំណាត់ការនានាដែលធ្វើឡើងដោយស្នងការ បង្កឲ្យមានបន្ទុកការងារផ្នែកបទបញ្ជាបន្ថែមសម្រាប់ DMHC ។

ការចំណាយផ្នែករដ្ឋបាលដែលអាចមានចំពោះ Covered California ។ វិធានការនេះមិនដាក់ភារកិច្ចថ្មីនានាមកលើ Covered California នោះទេ ប៉ុន្តែវាអាចបង្កឲ្យមានការចំណាយនានាផ្នែករដ្ឋបាលបន្ថែម ។ ដំណើរការអនុម័តអត្រាតម្លៃថ្មីនេះដែលអនុវត្តដោយ CDI ទំនងជានឹងអាចធ្វើឲ្យដំណើរការអនុម័តយូរជាងនេះ សម្រាប់ផលិតផលធានារ៉ាប់រងជាលក្ខណៈបុគ្គល និងជាក្រុមតូចមួយចំនួន ។ ប្រសិនបើមានការពន្យារពេលយូរក្នុងការអនុម័តផលិតផលណាមួយ វាអាចបង្កឲ្យផលិតផលនោះនឹងមិនអាចត្រូវបានដាក់លក់ក្នុងអំឡុងពេលចុះឈ្មោះចំហបាន ។ ហេតុនេះ វាអាចជះឥទ្ធិពលសារពើពន្ធលើ Covered California ។ ឧទាហរណ៍ ៖ អាចមានការចំណាយបន្ថែម ដើម្បីផ្តល់ជំនួយអតិថិជនដល់បុគ្គលនានាដែលផ្លាស់ប្តូរទៅកាន់ក្រុមហ៊ុនធានារ៉ាប់រងសុខភាពផ្សេងមួយទៀត ។ វាមិនច្បាស់ថាតើការពន្យារយូរក្នុងការអនុម័តអត្រាតម្លៃ នឹងអាចកើតមានស្ថិតក្រោមវិធានការនេះ ឬថាតើការពន្យាពេលទាំងនោះនឹងកើតឡើងញឹកញាប់ប៉ុណ្ណា ប្រសិនបើពួកវាកើតឡើងនោះ ។

សូមចូលទៅកាន់ *http://cal-access.sos.ca.gov* ដើម្បីមើលសេចក្តីលម្អិតអំពីលុយដែលត្រូវបានផ្តល់ជាវិភាគទានក្នុងការប្រកួតនេះ ។